# Living the Lotus

## Buddhism in Everyday Life

9
2023
VOL. 216





**Living the Lotus**
**Vol. 216 (September 2023)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីរព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិករីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



# លោភៈជាប្រភពនៃគ្រោះមហន្តរាយ

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## គ្រោះមហន្តរាយដែលបណ្តាលមកពីកិលេស

នៅជប៉ុនមានពាក្យសម្រាប់សំដៅរដូវលំហើយ“មេឃស្រឡះសេះស៊ីបានច្រើនឡើងធាត់មានកម្លាំង”គឺជារដូវដែលមនុស្សក៏អាចទទួលទានបានច្រើនដែរ។នៅរដូវលំហើយ ធាតុអាកាសបានទៅជាទន់ភ្លន់ មនុស្សក៏ទៅជាមានចំណង់ចង់បរិភោគ ទទួលទានអ្វីក៏ឆ្ងាញ់។ គឺជាប្រការគួរឱ្យត្រេកអរណាស់។ក៏ប៉ុន្តែសូមកុំពិសារច្រើនជ្រុលពេក ពិសារឱ្យល្មមៗដើម្បីកុំឱ្យស្តាយក្រោយ។

ប្រសិនបើជាសេចក្តីបារម្ភដោយឡើងទម្ងន់បន្តិចបន្តួចនៅពេលដែលមានចំណង់ចង់បរិភោគហើយពិសារបាន  យើងអាចដោះស្រាយបានដោយបន្ថយចំណុះអាហារ ក៏ប៉ុន្តែដូចដែលព្រះសម្មាសម្ពុទ្ធលោកបានមានពុទ្ធដីកាប្រៀនប្រដៅយើងថា៖“នៅពេលដែលមនុស្សខ្វារកចង់បាននេះផងនោះផងពេលនោះកិលេសទាំងឡាយទាំងពួងបានយកជ័យជម្នះលើអ្នកនោះបានហើយគ្រោះភ័យន្តរាយនឹងជាន់ឈ្លីអ្នកនោះនឹងបាតជើង”។ព្រះពុទ្ធដីកានេះចង់បង្ហាញថាមនុស្សយើងបើកាន់តែចង់បានអ្វីខ្វារកឡើងកាលណា ការលោភលន់នោះនឹងផ្តល់ទៅដល់រាងកាយគាត់នូវការឈឺចាប់ប៉ុននោះដែរ។ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលការលោភលន់វាទៅហួសព្រំដែនទៅ ហើយត្រូវ“គ្រោះភ័យន្តរាយ”ជាន់ឈ្លីនឹងបាតជើងនេះមិនមែនជារឿងតូចតាចល្មមៗទេ។

ដូចដែលមានចែងនៅក្នុងគម្ពីរសត្តនិបាត៖“នៅពេលដែលយើងខ្វារកចង់បានស្រែចំការ ដីធ្លីផ្ទះសម្បែង ស្រីញី ឬញាតិសន្តានឬអ្វីនានាដែលជាចំណង់ជ្រុលពេកទៅ ”កាលណាមនុស្សយើងលោភចង់បានលុយកាក់ ទ្រព្យសម្បត្តិជ្រុលពេកឬមួយក៏មានក្តីស្រឡាញ់នរណាម្នាក់ជ្រុលពេកទៅនឹងនាំឱ្យកើតចិត្តប្រច័ណ្ឌ ច្រណែន ស្អប់ចំពោះខ្លួនឯងនិងអ្នកដទៃ ហើយកត្តាទាំងនេះជាមូលហេតុនាំឱ្យមានទំនាស់ដែលជាភ័យន្តរាយ។

ឬមួយក៏នាំឱ្យមានគេស្អប់ខ្ពើម គេពេបជ្រាយថា ៖“ម្នាក់នោះជាមនុស្សលោភលន់សំបើមណាស់” ដែលនាំឱ្យទៅជាស្រ្តេះជះឥទ្ធិពលដល់រាងកាយដែលជាភ័យន្តរាយដែរ។

ព្រះសម្មាសម្ពុទ្ធទ្រង់មានពុទ្ធដីកាថា៖“ជនណាដែលកើតមានលោភៈ នៅពេលដែលបំពេញ

ចំណង់ចិត្តនោះមិនបាន អ្នកនោះក៏នឹងឈឺចាប់ដូចជាត្រូវបានគេបាញ់នឹងព្រួញ ”។នៅសម័យនោះក្នុងការពិតព្រះសម្មាសម្ពុទ្ធលោកបានទតឃើញឬបានស្តាប់ឮគេនិយាយពីមនុស្សបែបនោះថាពួកគេមានទុក្ខឈឺចាប់នឹងព្រះនេត្រនិងព្រះកាណ៌ផ្ទាល់របស់ព្រះអង្គ។ម្យ៉ាងទៀតនៅពេលដែលលោភៈនោះវាមានកម្រិតជ្រុលពេកទៅមនុស្សនឹងឈ្លោះប្រកែកជាមួយគេឯងមិនលោះពេលជួនកាលទៅក៏ត្រូវគេប្រើកម្លាំងបាយវាយតប់ឱ្យមានរបួសដែលជាគ្រោះមហន្តរាយផងដែរ។ព្រះសម្មាសម្ពុទ្ធទ្រង់បានឃើញអ្នកដែលស្វះស្វែងរកលាភសក្ការៈដោយលោភៈ មិនសូវមានអ្នកដែលមានសុខភាពល្អហើយតែងតែមានទុក្ខព្រួយឈឺចាប់។

ខុសពីសត្វដែលរស់ត្រឹមតែមួយចំអែត មនុស្សគឺជាសត្វដែលរស់នៅក្នុងសង្គម។ យើងជាមនុស្សជួនកាលមិនអាចទប់ចិត្តលោភលន់បានទេ។ដោយសារតែបែបនេះយើងតោងតែទប់ចំណង់ចិត្តដោយមិនត្រូវបំភ្លេចចិត្តគិតពីគេពីឯងហើយខិតខំព្យាយាមប្រត្តិបត្តិចិត្តធម៌ជារៀងរាល់ថ្ងៃឡើយ។

## រីករាយនឹងគ្រប់គ្រាន់

ចំណង់របស់មនុស្សមិនមែនជាអ្វីដែលអាក្រក់នោះទេ។ព្រះសម្មាសម្ពុទ្ធព្រះអង្គ“មានចំណង់ចង់ស្រោចស្រង់មនុស្សសត្វគ្រប់រូប”។ចំណង់នេះគឺជាចំណង់ដ៏ធំធេង។ជាមួយនឹងព្រះទ័យដែលចាក់ឫសទៅជ្រៅប្រកបទៅដោយមេត្តានិងព្រះទ័យគិតពីអ្នកដទៃព្រះអង្គក៏មានចំណង់ដ៏ធំមួយគឺស្វែងរកសច្ចៈនិងធម៌ដើម្បីជួយឱ្យមនុស្សសត្វគ្រប់ៗរូបមានសុភមង្គលហើយទ្រង់ក៏បានសម្រេចនូវសេចក្ដីប្រាថ្នានោះ។ជាការពិតណាស់ ចំណង់នោះក៏បានត្បាញចូលមកក្នុងជីវិតរបស់យើងទាំងអស់គ្នាដូចនឹងព្រះពុទ្ធដែរហើយវាបានទៅជាប្រភពសម្រាប់លើកកំពស់និងការចំរើនលូតលាស់នៃមនុស្សជាតិ។

ក៏ប៉ុន្តែនៅពេលដែលយើងមិនអាចគ្រប់គ្រងលោភៈរបស់យើងបាន លោភៈនោះក៏ក្លាយទៅជា“កិលេស” ហើយកិលេសនោះវានាំឱ្យយើងបារម្ភយើងឈឺចាប់។នៅពេលដែលមិនបានដូចចិត្តយើងក៏មានទុក្ខ ហើយដើម្បីនឹងបំពេញចិត្តខ្លួនឯង យើងលែងគិតពីដែនកំណត់ហើយធ្វើឱ្យទំនាក់ទំនងជាមួយនឹងអ្នកដទៃទៅជាមិនប្រសើរដែលជាហេតុនាំឱ្យកាន់តែមានទុក្ខលំបាកឡើង។ព្រះពុទ្ធសាសនាបង្រៀនឱ្យ “ចង់តិចហើយស្គាល់គ្រប់គ្រាន់”។ពោលគឺត្រូវចេះទប់ចំណង់ចិត្តហើយស្គាល់គ្រប់គ្រាន់។ទោះជាដឹងថាប្រសិនបើយើងអាចប្រតិបត្តិបែបនេះបានយើងនឹងអាចចៀសវាងការរត់លឿនស្លេវដូចព្យុះសំដៅទៅរកចំណង់ដែលបណ្ដាលឱ្យមានជាការឈឺចាប់បានក្ដី ក៏យើងជាមនុស្សមិនអាចនឹងធ្វើទៅបានដែរ។

មួយវិញទៀតខ្ញុំព្រះករុណាអាត្មាភាពសូមណែនាំពាក្យមួយ។គឺថាប្រសិនបើយើងប្ដូរអក្សរ“តិច”ដែលមាននៅក្នុងពាក្យថា “ចង់តិច” ទៅជា“តូច”យើងក៏បានពាក្យថា“ចង់តូច ស្គាល់គ្រប់គ្រាន់” វិញ។ទោះបីជាមើលទៅមិនសូវជាឃើញប្ដូរន័យអ្វីធំដុំក៏មែនពិត ក៏ប៉ុន្តែបើមើលតាមន័យជាភាសាបាលីវិញ “ចង់តូច ស្គាល់គ្រប់គ្រាន់” មានន័យថា សប្បាយចិត្តនឹងមានអ្វីដែលល្មមគ្រប់គ្រាន់។

ព្រះគ្រូថាំងចេងលោកបានប្រើពាក្យ“រីករាយនឹងគ្រប់គ្រាន់”ជំនួសពាក្យ“ស្គាល់គ្រប់គ្រាន់”។

បើដឹងថាការបំពេញចំណង់ដែលចាំបាច់គឺជាសេចក្ដីរីករាយហើយចង់ក្រេបរសជាតិនៃសេចក្ដី“រីករាយដោយបានគ្រប់គ្រាន់” ចំណង់យើងក៏នឹងអាចទប់ស្កាត់បានលើសពីនេះទៅទៀតវាហាក់ដូចជាស្រួលទទួលយកនិងនាំឱ្យចិត្តបានធូរស្រាលជាងពាក្យថា “ស្គាល់គ្រប់គ្រាន់”។ ម្យ៉ាងទៀតវាអាចឱ្យយើងអាចគ្រប់គ្រងចិត្តលោភលន់របស់យើងបានដែរផងក៏មិនដឹង។ខ្ញុំព្រះករុណាអាត្មាភាពយល់ថាសេចក្ដីរីករាយនឹងគ្រប់គ្រាន់នាំឱ្យយើងមានសុខភាពល្អហើយជីវិតយើងក៏មានសុភមង្គល។

『ទស្សនាវត្តីកូសេ』 លេខខែ៩ឆ្នាំ២០២៣

# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**twitter**

We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)